# ខ្លឹមសារអត្ថបទសង្ខេប

## សវនាការដោយផ្ទាល់ (trial in person)

Johann Bair, The International Covenant on Civil and Political Rights and Its (First) Optional Protocol, A Short Commentary Based on Views, General Comments and Concluding Observations by the Human Rights Committee, pp. 66-69, 2005

**បទប្បញ្ញត្តិ៖** មាត្រា១៤ (ក.ឃ) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ៖ ៣.*ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ដូចខាងក្រោម៖*

(ឃ) *ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានប្រាប់ឲ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួយការច្បាប់ ហើយត្រូវទទួលបានជំនួយការច្បាប់សម្រាប់ខ្លួន ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌ តម្រូវឲ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃនៅគ្រប់ករណីបែបនេះ បើជនជាប់ចោទគ្មានមធ្យោបាយគ្រប់គ្រាន់ ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេ។*

**១.** សវនាការ តម្រូវឲ្យមានការចូលរួមផ្ទាល់ដោយជនជាប់ចោទ តាមគោលការណ៍នៃផ្ទាល់មាត់ (principle of orality)។ នេះទាមទារឲ្យតុលាការជូនដំណឹង អំពីពេលវេលាសវនាការឲ្យបានដឹងក្នុងអំឡុងពេលសមស្រប ដើម្បីគាត់អាចរៀបចំការពារខ្លួនបាន។ សវនាការ អាចធ្វើឡើងដោយអវត្តមាន (*in absentia*) នៅពេលដែល ជនជាប់ចោទ ត្រូវបានជូនដំណឹងត្រឹមត្រូវ តែមិនបានចូលរួមដោយគ្មានហេតុផលសមស្រប។ ទោះបីជាយ៉ាងនេះក្តីក្នុងសំណុំរឿង មានទោសប្រហារជីវិត ជនជាប់ចោទ ត្រូវតែមានវត្តមានក្នុងសវនាការ។ ក្នុងអំឡុងពេលសវនាការ ចៅក្រមអាចប្តូរនូវប្រភេទបទល្មើស (legal characterization)។ ការមិនទទួលបានព័ត៌មាននេះ ឬពិបាកក្នុងការការពារខ្លួន ជនជាប់ចោទ អាចមិនចូលខ្លួន ដែលនាំឲ្យមានសវនាការដោយគ្មានវត្តមានរបស់គាត់។ ក្នុងករណីមានការផ្លាស់ប្តូរនេះ ចៅក្រមត្រូវជូនដំណឹងដល់ជនជាប់ចោទ ដើម្បីគាត់ត្រៀមការពារខ្លួន ឬ អាចសុំពន្យាពេលសវនាការ។

**២.** មាត្រា១៤ (៣.ឃ) មានខ្លឹមសារជាន់គ្នានឹងមាត្រា ១៤(៣.ខ) ស្តីពី សិទ្ធិទទួលបានតំណាងផ្លូវច្បាប់ (legal representation)។

**ខ្លឹមសារដកស្រង់៖** *នីតិវិធីដោយគ្មានវត្តមានជនជាប់ចោទ អាចអនុញ្ញាតឲ្យមាន ក្នុងបំណងនៃរដ្ឋបាលតុលាការសមស្រប នៅពេលជនជាប់ចោទ ទោះបីមានការទទួលបានការជូនដំណឹងនូវនីតិវិធីគ្រប់គ្រាន់ជាមុន តែបដិសេធនូវឱកាសក្នុងការចូលរួមដោយផ្ទាល់ក្នុងដំណើរការនីតិវិធី* (UN HRC, General Comment No. 13)។

**ពាក្យគន្លឹះ៖** សវនាការដោយផ្ទាល់, តំណាងតាមផ្លូវច្បាប់, ការរៀបចំខ្លួន, ទោសប្រហារជីវិត